# ច្បាប់វិន័យនៃរបៀបនៅ 住まい方のルール（カンボジア語版）

នៅក្នុងគេហដ្ឋានរួម ដែលមានជនគ្រប់ប្រភេទរស់នៅជាមួយគ្នាការគោរពតាមច្បាប់ (ច្បាប់វិន័យនៃរបៀបនៅ) នេះធ្វើអោយយើងរស់នៅរួមគ្នានោះមានភាពងាយស្រួល សុខសាន្ត ទៅវិញទៅមករាល់ថ្ងៃ។

## របៀបចោលសំរាម ゴミの出し方（だ かた）

របៀបចោលសំរាម យោលទៅតាមតំបន់ ក្រុង ស្រុក ភូមិ របស់អ្នក។ សូមសួរទៅ បុគ្គលិកហាងអសង្ហារិមទ្រព្យឬអ្នកជិតខាង នូវប្រភេទនៃសំរាម ថ្ងៃចោលនឹងម៉ោងពេល។

**◆សួរអ្នកជិតខាង ឬបុគ្គលិកហាងអសង្ហារិមទ្រព្យ**

①ការបែងចែកសំរាមដែលដុតឆេះ នឹងសំរាមដុតមិនឆេះ។
②របៀបបែងចែក នឹងរបៀបចោលសំរាមភោគទ្រព្យ។
③ថ្ងៃចោលសំរាមនឹងម៉ោងពេល។
④កន្លែងចោលសំរាម។
⑤របៀបចោលសំរាមធំៗ



សំរាមដុតឆេះ



សំរាមដុតមិនឆេះ



សំរាមភោគទ្រព្យ



សំរាមធំៗ



＊ដប,កំប៉ុង,កាសែតអាន, ទស្សនាវត្តី,ក្រណាត់,សំលៀកបំពាក់,ដបជ័រជាដើម មានរបៀបគេយកទៅចោលនៅថ្ងៃខុសៗគ្នា តាម តំបន់។

## របៀបប្រើប្រាស់ផ្ទះបាយ 台所の使い方（だいどころ つか かた）

ប្រើប្រាស់ផ្ទះបាយ ឱ្យបានស្អាតបាត
ជើងលាងចានមិនត្រូវចាក់ខ្លាញ់ឬសំរាមតាមមាត់ប្រេកបង្ហូរទឹកឡើយ។ ព្រោះវានាំឱ្យស្ទះបំពង់បង្ហូរទឹកចោល។
ការចាក់ខ្លាញ់ចោលតាមជើងលាងចានតែម្តងនោះ នាំឱ្យកខ្វក់ដល់ស្ទឹងនឹងសមុទ្រ។



＊នាំឱ្យ កខ្វក់ដល់ស្ទឹងឬសមុទ្រ។ សូមចោលខ្លាញ់ជាមួយសំរាមដុតឆេះ ដោយចាក់វាខ្ចប់នឹងក្រដាសកាសែតជាដើម។

## សំលេងរំពងឬខ្ទ័រ 生活騒音(せいかつそうおん)

គេហដ្ឋានរួម វាអាចឮសំលេងរំពងឬសំលេងខ្ទ័របានដោយងាយ ពីបន្ទប់មួយទៅបន្ទប់មួយ ពីជាន់លើទៅក្រោមពីក្រោមទៅលើ។ ជាពិសេសនៅពេលយប់ជ្រៅដល់ពេលទាបភ្លឺ សូមប្រយ័ត្នចំពោះសម្លេងរំពងឬខ្ទ័រកុំឱ្យមានឡើយ។

◆ **សូមប្រយ័ត្ននូវសំលេងខ្ទ័ររំពងទាំងនេះ**



ដូចជាសំលេងទូរទស្សន៍,ម៉ាញេ



សំលេងឧបករណ៍តន្ត្រី



សំលេងនិយាយគ្នាខ្លាំងៗ



សម្លេងម៉ាស៊ីនបោសផ្ទះ,ម៉ាស៊ីនបោកគក់



សម្លេងងូតទឹកខ្លាំង



សម្លេងបើកបិទទ្វារខ្លាំងៗ

## របៀបប្រើប្រាស់បន្ទប់ទឹក និងបង្គន់ 浴室(よくしつ)トイレの使(つか)い方(かた)

កាលណាទឹកបង្ហូរចោលនៃបន្ទប់ទឹកឬបង្គន់ស្ទះ វានឹងហៀរមកក្រៅបណ្តាលឱ្យកើតរឿងរីករវ ជាមិនខាន។
ព្រោះត្រូវសងគេបើផ្ទះជាន់ក្រោមមានការខូចខាតដោយសារទឹកហៀរពីនេះទៅ។



កុំចោលសសៃសក់,រោម
តាមច្រកបង្ហូរទឹកចោលនៃបន្ទប់ទឹក។





ក្រដាសបង្គន់



ក្រដាសជូតមាត់



សំឡីស្ត្រី

ហើយក៏កុំប្រើក្រដាសផ្សេងក្រៅពីក្រដាសបង្គន់(ក្រដាសប៉ុយ)បង្ហូរក្នុងបង្គន់ឱ្យសោះ។

## របៀបប្រើប្រាស់បេឡង់ដា(រានហាលក្រៅផ្ទះ) ベランダの使い方

នៅពេលហាលពូក,ភួយ,ឬដាក់ជើងដំណាំនៅបេឡង់ដា សូមប្រយ័ត្នកុំឱ្យធ្លាក់ទៅក្រោម។ ហើយចូរប្រយ័ត្ន កុំដាក់វត្ថុឬរបស់ផ្សេងៗ នៅបេឡង់ដាដែលគេទុកសំរាប់ដើរឆ្លងពេលអាសន្ន។



ប្រយ័ត្នរបស់ហាលឬដំណាំធ្លាក់ទៅក្រោម



កុំដាក់ឥវ៉ាន់តាមច្រករត់គេចពេលអាសន្ន

## ចំណែកកន្លែងរបស់ប្រើរួម 共有部分の使い方

ក្រៅពីផ្ទះរបស់ខ្លួននៅ ដូចជាច្រកចេញចូលខាងក្រៅ និងជណ្តើរគឺជារបស់ផ្នែកប្រើរួម។ ហើយវាក៏ជាច្រកឬផ្លូវ សំរាប់រត់គេច នៅពេល មានអគ្គីភ័យឬរញ្ជួយផែនដី។ ដូច្នេះចូរកុំយករបស់ផ្ទាល់ខ្លួនទៅដាក់តាមជណ្តើរឬច្រកដើរខាងក្រៅដាច់ខាត។



នៅច្រកផ្លូវដើរឬតាមជណ្តើរ កុំយករបស់របរផ្ទាល់ខ្លួនទៅដាក់ឡើយ

## កន្លែងដាក់កង់ ចំណតរថយន 自転車置き場・駐車場

កង់ត្រូវដាក់ នៅកន្លែងចំណតកង់ឬ កន្លែងដែលគេឱ្យដាក់ តម្រៀបតាមជួរ។ ចំពោះអ្នកមានរថយន្ត(ឡាន) សូមជួលកន្លែងចត។ ព្រោះនៅតាមចញ្ចើមថ្នល់ មិនអាចចតរថយន្តបានទេ។




កង់ត្រូវយកទៅដាក់នៅកន្លែងដែលគេឱ្យដាក់ ដើម្បីកុំឱ្យទើសទែងដល់អ្នកដើរចេញចូល

## មើលបញ្ជាក់នូវលិខិតកិច្ចសន្យា(កុងត្រា) 契約書で確認すること

(けいやくしょ　かくにん)

ការប្រើប្រាស់បន្ទប់នៃគេហដ្ឋានរួម មានរបៀបខុសគ្នាបន្តិចបន្តួច យោលទៅតាមកន្លែងផ្ទះនោះ។
សូមអានបញ្ជាក់ក្នុងលិខិតកិច្ចសន្យា នៃការហាមប្រាមរបស់គេហដ្ឋានរួម ដែលលោកអ្នក កំពុងនៅ។

**◆នេះជាការហាមប្រាមខ្លះនៅនៃគេហដ្ឋានរួម**



ហាមមិនឱ្យចិញ្ចឹមសត្វពាហនៈ



ហាមវាយដែកគោលឬលាបថ្នាំ



ហាមអ្នកក្រៅពីអ្នកមានឈ្មោះក្នុងកិច្ចសន្យានៅជាមួយ



ជាផ្ទះសំរាប់នៅ ហាមមិនឱ្យយកធ្វើជា ហាងលក់ទំនិញឬការិយាល័យធ្វើការទេ ។

**តើលោកអ្នកមានដឹងទេ? ថាមាន**

## សមាគមស្រុក,សមាគមស្វ័យភាព 町内会・自治会

(ちょうないかい　じちかい)




ជាទូទៅ ក្នុងប្រទេសជប៉ុន នៅទីណាក៏មានសមាគមគេហៅថា <*សមាគមក្នុងស្រុក*>
ឬមួយ<*សមាគមស្វ័យភាព*> ដែលកើតឡើងដោយ អង្គការនៃអ្នកស្រុក។
សមាគមទាំងនេះមានសកម្មភាព ឧទាហរណ៍ដូចជា: បន្ទះសារាចរ
(បន្ទះក្តារដែលមានភ្ជាប់ក្រដាសឱ្យដំណឹងផ្សេងៗ ដែលបានមកពីសាលាក្រុង,ឬពីកន្លែងសង្គមកិច្ច,
ហើយគេផ្សាយដោយហុចបន្ទះក្តារនេះតៗគ្នាតាមផ្ទះ)
ការការពារឧក្រិដ្ឋកម្ម,ការហ្វឹកហ្វឺនពេលអាសន្ន,សកម្មភាពទាក់ទងរវាងគ្នានឹងគ្នានៃអ្នកស្រុក
ដោយមានធេ(កម្មវិធីធ្វើបុណ្យទានទិង ព្រឹត្តិហេតុផ្សេងៗ)។ សមាគមទាំងនេះ ធ្វើការបំរើអ្នកស្រុក
ដោយកម្រៃចំណូលពីសមាជិក(អ្នកស្រុកបង់លុយទៅឱ្យសមាគម)។
បើជាអ្នកស្រុក ទោះជាជនបរទេសក៏ដោយ ក៏អាចចូលរួមបានដែរ។
បើមានបុគ្គលិកអ្នកធំនៃសមាគម គេមកសួរសុខទុក្ខ និយាយអំពីរឿងនេះ
សូមសាកស្តាប់នូវការនិយាយរបស់គេផង។

ចុះខែ ឆ្នាំ២០០១ ក្រុមគំរោងការអន្តរជាតិផ្នែកប្រជាជនខេត្ត ខេត្តកាណាហ្គាវ៉ា តលេ។០៤៥-២១០-១១១១(តំណាង)